archive.today
webpage capture

Saved from https://www.vodkhmer.news/2020/05/13/more-than-1000-factory-workers-tak search
no other snapshots from this url

22 Mar 2024 07:50:39 UTC

All snapshots from host www.vodkhmer.news

Webpage Screenshot share download .zip report bug or abuse Buy me a coffee



# កម្មកររោងចក្រជាង១ពាន់នាក់នៅក្រុងតាខ្មៅផ្អាកការតវ៉ាទាមទារប្រាក់ឈ្នួល ក្រោយថៅកែពន្យារពេល

ព័ត៌មានជាតិ ការងារ សេដ្ឋកិច្ច

លោក យុគ សុគន្ធ | ១៣ ឧសភា ២០២០ ម៉ោង ១៦:០៥




កម្មករបម្រើការងារនៅរោងចក្រ អេហ្វ អឹម អេហ្វ មេនូហ្វេកធីរីង (FMF MANUFACTURING CO.,LTD) ស្ថិតក្នុងក្រុងតាខ្មៅ ខេត្តកណ្ដាល បានផ្អាកការទាមទារទៅថៅកែឱ្យបើកប្រាក់ឈ្នួល ក្រោយពេលថៅកែពន្យារពេលបើកប្រាក់ឈ្នួល និងបញ្ចប់កិច្ចសន្យាការងារ ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។ (យុគ សុគន្ធ)

កម្មករជាង ១ពាន់នាក់ បម្រើការងារនៅរោងចក្រ អេហ្វ អឹម អេហ្វ មេនូហ្វេកធីរីង (FMF MANUFACTURING CO .,LTD) ស្ថិតក្នុងក្រុងតាខ្មៅ ខេត្តកណ្ដាល បានផ្អាកការតវ៉ា ២ថ្ងៃហើយ ដើម្បីទាមទារទៅថៅកែឱ្យបើកប្រាក់ឈ្នួល ដោយពួកគេប្រាប់ថា ជីវភាពរបស់ពួកគេកំពុងខ្វះខាត។

កម្មករផ្នែកតុកាត់ លោក ស្រេង ចំរើន ប្រាប់វីអូឌីនៅកន្លែងតវ៉ាមុខរោងចក្រថា រោងចក្រ FMF មានកម្មករ-កម្មការិនីប្រហែលជាង ១ពាន់នាក់ បានផ្អាកការតវ៉ាអត់ធ្វើការងារទាំងអស់គ្នានៅថ្ងៃនេះ បន្ទាប់ពីថៅកែពន្យារពេលបើកប្រាក់ឈ្នួល និងបញ្ចប់កិច្ចសន្យាការងារកម្មករ ២៥០នាក់។

លោក ស្រេង ចំរើន អះអាងថា លោកត្រូវបានថៅកែបញ្ចប់កិច្ចសន្យាការងារនៅក្នុងខែនេះ ហើយថៅកែ FMF បានជំពាក់ប្រាក់ឈ្នួលរបស់លោក និងកម្មករដទៃទៀត ១ខែពេញ ដោយចាប់តាំងពីថ្ងៃទី១០ ខែមេសា រហូតដល់ថ្ងៃទី១៣ ខែឧសភានេះ គឺថៅកែមិនទាន់បានបើកលុយឱ្យកម្មករនៅឡើយទេ ទាំងកម្មករដែលត្រូវបានបញ្ចប់កិច្ចសន្យាការងារ និងកម្មករដែលមិនត្រូវបានបញ្ចប់កិច្ចសន្យាការងារ។

> លោកបន្ថែមថា៖ **«គាត់ [ថៅកែ] បញ្ឈប់ពួកខ្ញុំភ្លាមៗបាន ចុះហេតុអីគាត់មិនបើកលុយឱ្យពួកខ្ញុំភ្លាមៗបាន ហើយអូសបន្លាយ ១ខែហើយ? អ៊ីចឹង ខ្ញុំសុំអំពាវនាវដល់អាជ្ញាធរ និងក្រសួងការងារ ជួយដល់កម្មករនៅរោងចក្រ FMF ផង ដោយជួយជំរុញឱ្យថៅកែរោងចក្រហ្នឹងបើកឱ្យលុយពួកខ្ញុំផង»។**

កម្មការិនីដែលជាស្ត្រីមេម៉ាយ អ្នកស្រី ស្រស់ ធី អាយុ ៥០ឆ្នាំ បានរៀបរាប់ថា អ្នកស្រីជារម្កពីការខ្វះខាតក្នុងជីវភាពគ្រួសារ និងជំពាក់បំណុលគេទ្វេដង ខណៈដែលអ្នកស្រីក៏ត្រូវបានថៅកែបញ្ឈប់ពីការងារ ហើយមានវ័យកាន់តែចាស់ ពិបាករកការងារកន្លែងថ្មីធ្វើ និងត្រូវទទួលបន្ទុកចិញ្ចឹមកូន ៤នាក់ក្នុងគ្រួសារទៀតនោះ។

> អ្នកស្រីបន្ថែមថា៖ **«ពេលអត់ការងារធ្វើ គឺខ្ញុំអត់លុយឱ្យថ្លៃផ្ទះជួល ទឹកភ្លើង ថ្លៃកូនចាយវាយ។ ឥលូវ ខ្ញុំជំពាក់លុយថ្លៃផ្ទះជួលគេ ១ខែហើយ គេមកទារ ខ្ញុំអត់មានអីឱ្យគេ ខ្ញុំអង្វរសុំគេពន្យារពេល។ ហើយខាងរោងចក្របញ្ឈប់ខ្ញុំ អត់បើកលុយឱ្យខ្ញុំអ៊ីចឹង ខ្ញុំបានលុយណាបង់សងគេ ហើយខ្ញុំជាស្ត្រីមេម៉ាយមានកូន ៤នាក់តូចៗនៅផ្ទះ គ្នាបានអីញ៉ាំ បើគេមិនឱ្យលុយអ៊ីចឹង»។**

ប្រធានរដ្ឋបាលរោងចក្រ FMF លោក សុខ ផេង ប្រាប់ថា ក្រុមហ៊ុនបើកប្រាក់ឈ្នួលឱ្យកម្មករយឺតយ៉ាវ គឺដោយសារក្រុមហ៊ុនមានបញ្ហាផ្នែកហិរញ្ញវត្ថុ ពោលគឺគ្មានអ្នកបញ្ជាទិញ។ លោកបន្តថា ដោយសារគ្មានលុយបង្វិលបើកឱ្យកម្មករទាន់ពេលនោះ គឺថៅកែបានសុំពន្យារបើកដល់ថ្ងៃទី២២ ខែឧសភា ប៉ុន្តែ លោកថា ក្រុមហ៊ុននឹងខិតខំកៀរគរលុយយកមកបើក ឱ្យបានមុនថ្ងៃទី២២ ខែឧសភា។

ប្រធានរដ្ឋបាលរោងចក្ររូបនេះ បានអំពាវនាវឱ្យកម្មករយោគយល់ និងកុំស្តាប់សហជីពមកពីខាងក្រៅ ដែលលោកថា សហជីពទាំងនោះកំពុងញុះញង់ឱ្យកម្មករតវ៉ា ហើយធ្វើឱ្យកម្មករបាត់បង់ការងារធ្វើ។

> លោកបន្ថែមថា៖ **«រោងចក្រនេះ រាល់ខែ គឺបើកលុយឱ្យកម្មករមុនថ្ងៃរហូតហ្នឹង។ ទើបតែខែនេះទេដែលមានបញ្ហា ដោយសាររឿងកូវីដហ្នឹង។ យើងថា បើកឱ្យគាត់នៅថ្ងៃទី១២ ហ្នឹង ប៉ុន្តែ ដល់ថ្ងៃទី១២ យើងមានការរាំងស្ទះលុយ។ យើងក៏បានជួបជាមួយគាត់ សុំគាត់លើកទៅបើកនៅថ្ងៃទី២២ ដោយមូលហេតុទំនិញយើងចេញអត់បានទេ។ ហើយការផ្លាស់ប្តូរទំនិញ ឬវត្ថុធាតុដើមគឺអត់បានទាំងអស់។ អ៊ីចឹង យើងសុំឱ្យកម្មករគាត់យោគយល់ ប៉ុន្តែ កម្មករគាត់អត់ព្រមទេ គាត់ខឹង ហើយគាត់ព្យាយាមហៅអ្នកនេះ អ្នកនោះមកដោះស្រាយវិញ»។**

បើតាមលោក សុខ ផេង រោងចក្រ FMF មានកម្មករ ១០៤០នាក់ ប៉ុន្តែ កម្មករអះអាងថា រោងចក្រនេះមានកម្មករ ១៦០០នាក់ ក្នុងនោះ ២៥០នាក់ ត្រូវថៅកែបញ្ឈប់ពីការងារកាលពីខែមុន។

ប្រធានមន្ទីរការងារខេត្តកណ្តាល លោក ធុល នាង ប្រាប់វិអូឌីថា ករណីវិវាទការងារនៅរោងចក្រ FMF គឺលោកបានចាត់មន្ត្រីចុះសម្របសម្រួលដោះស្រាយហើយ។ លោកថា ថៅកែសន្យាបើកលុយឱ្យកម្មករនៅថ្ងៃទី២២ ខែឧសភាខាងមុខនេះ ហើយកម្មករក៏យល់ព្រមដែរ។

> លោកបន្ថែមថា៖ **«យើងសម្របសម្រួលដោះស្រាយរួចហើយ។ ក្នុងកំណត់ហេតុ គាត់បានឯកភាពគ្នាហើយ។ ក្រុមការងារយើងកំពុងធ្វើបន្តទៀត ដោយក្នុងកំណត់ហេតុហ្នឹង ថៅកែគាត់សន្យាបើកលុយដែលកម្មករទាមទារហ្នឹងនៅថ្ងៃទី២២ ខែឧសភា ហើយកម្មករក៏គាត់យល់ព្រមដែរ»។**

កាលពីថ្ងៃទី៨ ខែឧសភា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានលើកឡើងថា ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ផលិតស្បែកជើង និងផលិតផលផ្សេងទៀតនៅកម្ពុជា កំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារតែគ្មានអ្នកបញ្ជាទិញ ខណៈដែលជំងឺកូវីដ១៩ កំពុងរីករាលដាល។

សមាគមមួយនេះ អះអាងថា ដោយសារឧស្សាហកម្មនេះរងគ្រោះធ្ងន់ធ្ងរពេក បានធ្វើឱ្យរោងចក្រចំនួន ១៨០ បានព្យួរផលិតកម្មរបស់ខ្លួន ខណៈរោងចក្រចំនួន ៦០ផ្សេងទៀត នឹងព្យួរផលិតកម្មរបស់ខ្លួននៅពេលខាងមុខដែរ ដោយសារមិនអាចទ្រទ្រង់បាននូវបន្ទុកចំណាយរបស់រោងចក្រ ខណៈចំណូលរបស់ពួកគេកាន់តែធ្លាក់ចុះខ្លាំង។

---

រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការ

សរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

អត្ថបទទាក់ទង

## សូមផ្តល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *
សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *
សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)
បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វិអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *
សូមបញ្ចេញមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

ចុចបញ្ជូន

ព័ត៌មានថ្មីៗ | បោះឆ្នោត




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រីរឿងផ្តល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល



១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤

ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ




១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣

អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង



ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ មាណ្ណារ៉ា ជាទីប្រឹក្សាលោក ហ៊ុន សែន






VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្តល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។

info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

GET IT ON Google Play
Download on the App Store






© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម